## ១. លក្ខណៈទូទៅ

ជាទូទៅជំងឺភ្នែកចាប (Bird's eye spot disease) តែងតែកើតមានឡើងនៅក្នុងថ្នាលបណ្ដុះកូន អំឡុងពេលនៃអាកាសធាតុស្ងួត។ ជំងឺប្រភេទនេះមានកើតច្រើននៅលើកៅស៊ូ ហើយវាមិនបណ្ដាលឱ្យដើមកៅស៊ូងាប់ទេ ប៉ុន្តែវាអាចធ្វើឱ្យដើមកៅស៊ូទាំងមូលចុះខ្សោយនិងជ្រុះស្លឹក។ កូនកៅស៊ូដែលកើតជំងឺនេះដុះលូតលាស់យឺតយ៉ាវក្របានយកទៅដាំឬក្របានបំប៉ៅ។ ភាគច្រើនវាកើតនៅលើដើមកៅស៊ូដែលដាំនៅលើដីខ្វះជីជាតិ ។

## ២. រោគសញ្ញាជំងឺ

ជំងឺភ្នែកចាបមានស្នាមអុជរាងមូលទំហំ ១-៣ម.ម. មានចំណុចភ្លឺថ្លានៅចំកណ្ដាល និងព័ទ្ធជុំវិញដោយរឹមតូចពណ៌ត្នោត។ ស្លាកស្នាមអុជនេះបណ្ដាលមកពីផ្សិតរាតត្បាតនៅពេលស្លឹកធំពេញរូបរាង ប៉ុន្តែស្លឹកនៅខ្ចីនៅឡើយ។ នៅលើស្លឹកខ្ចី ការរាតត្បាតនៃជំងឺធ្វើឱ្យមានស្លាកស្នាម អុចពណ៌ខ្មៅនៅរាយប៉ាយនិងរាលដាលនៅពេញផ្ទៃស្លឹកហើយធ្វើឱ្យស្លឹកជ្រីវជ្រួញ។ នៅលើស្លឹកចាស់ មានស្នាមដំបៅ (lesion) ជាចំណុចតូចៗមានព៌ណត្នោត។ ជំងឺនេះត្រូវបានឃើញកើតមាននៅលើកូនកៅស៊ូស៊ីដលីង ច្រើនជាងកូនកៅស៊ូបំប៉ៅ។ នៅលើដើមកៅស៊ូចាស់ ជំងឺភ្នែកចាប មិនឃើញកើតមានទេ ហើយក៏មិនសំខាន់នោះដែរ។



## ៣. ភ្នាក់ងារបង្កជំងឺ

ជំងឺភ្នែកចាប បង្កឡើងដោយផ្សិត *Drechslera heveae* ឬ *Helminthosporium heveae* ដែលបង្កើតនូវស្ប៉ (spores) វែងធំពណ៌ត្នោតក្រម៉ៅដែលអាចមើលឃើញដោយប្រដាប់ឆ្លុះកាន់ដៃ (hand lens)។ នៅពេលបញ្ចេញស្ប៉ គេឃើញស្ប៉ពណ៌ត្នោតស្រអាប់ជាច្រើនស្ថិតនៅចំកណ្ដាល នៃស្នាមអុជនៅផ្នែកខាងក្រោមផ្ទៃស្លឹក។ ស្ប៉ទាំងនោះនឹងបែកសាយភាយចេញដោយខ្យល់នាំទៅរយៈចម្ងាយឆ្ងាយ។

ទឹកភ្លៀង សន្សើម និង ទំនាក់ទំនងពីដើមមួយទៅដើមមួយ គឺជាមូលហេតុធ្វើឱ្យស្ប៉ដាច់ចេញពីស្នាមដំបៅទៅកន្លែងផ្សេងទៀត។ កាលណាបើជំងឺនេះកើតឡើងនៅក្នុងថ្នាលបណ្ដុះកូន វានឹងរាលដាលយ៉ាងឆាប់រហ័ស ហើយស្លឹកកៅស៊ូកម្រគេចផុតពីជំងឺនេះណាស់។ ក្រៅពីដើមកៅស៊ូ គេពុំឃើញមានរុក្ខជាតិផ្សេងទៀតជារុក្ខជាតិជម្រកនៃជំងឺផ្សិតនេះទេ។

